# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៣៤ ព្រទ.កសន-៩៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

លោកប្រធានតុលាការ ក្រុងព្រះសីហនុ

សូមជ្រាប។

**កម្មវត្ថុ:** ស្តីពីវត្ថុតាងក្នុងសំណុំរឿងព្រហ្មទណ្ឌ ។
**យោង:** លិខិតលេខ ២៣៨៧ ស.ហ.វ.គ.រ របស់ក្រសួងហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ។

ខ្ញុំសូមជម្រាបលោកជ្រាបថា ច្បាប់ស្តីពីពន្ធលើទំនិញនាំចូលនិងនាំចេញដែលបានប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី២៦-៧-៨៩ ត្រង់មាត្រា១៩ បានចែងថាការរឹបអូសវត្ថុតាងជាសមត្ថកិច្ចរបស់តុលាការ ។ ច្បាប់នេះនៅមានអនុភាពអនុវត្តរហូតដល់បច្ចុប្បន្ន ហើយក៏ពុំទាន់មានច្បាប់ណាមួយចែងផ្ទុយពីនេះ ឬកែប្រែច្បាប់នេះនៅឡើយ ។ មាត្រា១៦ នៃច្បាប់នេះបានចែងថាទីចាត់ការគយ និងរដ្ឋាករមានសិទ្ធិពិន័យ និងឃាត់ទុកទំនិញព្រមទាំងមធ្យោបាយដឹកជញ្ជូនដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ហើយអង្គការគយដោយមានការឯកភាពពីថ្នាក់លើអាចសម្រេចលក់ទំនិញឃាត់ទុក ដែលឆាប់ខូចគុណភាពទុកយូរមិនបាន ប៉ុន្តែក្នុងករណីមានការរឹបអូសទំនិញ ឬមធ្យោបាយដឹកជញ្ជូន ដែលត្រូវបញ្ជូនសំណុំរឿងទៅតុលាការសម្រេចនោះចាំបាច់ត្រូវមានវត្ថុតាងបើគ្មានវត្ថុតាងតុលាការមិនអាចជំនុំជម្រះសម្រេចរឹបអូសបានទេ ។

សេចក្តីដូចបានជម្រាបខាងលើសូមលោកប្រធានជ្រាបជាព័ត៌មាន ។

ជូនភ្ជាប់មកជាមួយនូវ:

សេចក្តីចតចម្លងលិខិតលេខ៧០៨ ព្រ.ទ.ភព-៩៥ ចុះថ្ងៃទី១៩-៧-៩ ១ច្បាប់

ធ្វើនៅភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៩៥

**រដ្ឋមន្ត្រី**

ចម្លងជូន
-អយ្យការនិងតុលាការគ្រប់ជាន់ថ្នាក់

**ចែម ស្ងួន**